International Organization for Migration (IOM)

The UN Migration Agency

ក្រុមលេខាធិការដ្ឋាន គ.ជ.ប.ជ
ចូល
លេខ: ០០៧៣/២២
ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២
បញ្ជូនមកពី IOM

លេខ:២២/១១៥/IOM

**គោរពជូន**

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**កម្មវត្ថុ៖** (១) សំណើកិច្ចសហការណ៍ និងស្នើសុំអញ្ជើញសមាជិកគណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូរ ដើម្បីចូលរួមសិក្ខាសាលាស្តីពី ប្រសិទ្ធភាពនៃកម្មវិធីជំនួយក្នុងការវិលត្រលប់ដោយស្ម័គ្រចិត្ត និងការធ្វើសមាហរណកម្ម នៅកម្ពុជា នៅព្រឹកថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២២
(២)សំណើសុំអញ្ជើញគណៈប្រតិភូកម្ពុជាសម្រាប់កិច្ចពិភាក្សាត្រៀម មុនចូលរួមកិច្ចប្រជុំស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) នៃការអនុវត្តច្បាប់រវាងប្រទេសកម្ពុជា និងប្រទេសថៃ នៅរសៀលនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២២

អន្តរជាតិទេសន្តប្រវេសន៍ (IOM) ប្រចាំនៅកម្ពុជា សូមធ្វើការកោតសរសើរដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ ព្រះរាជាណាចក្រកម្ពុជា និងមានសេចក្តីរីករាយសូមជម្រាបជូន **លោកជំទាវ** ថា អង្គការ IOM កំពុងធ្វើការសិក្សាស្រាវជ្រាវថ្លាមៗមួយដើម្បីវាយតម្លៃទិដ្ឋភាពនៃការធ្វើសមាហរណកម្មនៅក្នុងខេត្តបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង ដែលជាតំបន់ដែលមានចំនួនជនចំណាកស្រុកច្រើនជាងគេដែលបានត្រឡប់មកប្រទេសកម្ពុជាវិញដោយសារតែផលប៉ះពាល់ពីកូវីដ-១៩ ពីប្រទេសថៃ និងវាយតម្លៃនូវចន្លោះប្រហោងនៅក្នុងការផ្តល់សេវាដែលអាចកើតឡើងដោយសារកង្វះខាតនៃនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) ដែលកំពុងត្រូវបានអនុវត្ត ឬចន្លោះប្រហោងដែលអាចនឹងត្រូវបានដោះស្រាយឲ្យបានប្រសើរឡើងនូវនីតិវិធីប្រតិបត្តិការស្តង់ដារ ប្រសិនបើមានការចាំបាច់ត្រូវកែសម្រួលដើម្បីឆ្លុះបញ្ចាំងនូវបរិបទក្រោយជំងឺរីករាលដាល។

គោលបំណងសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ពីបទពិសោធន៍នៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មសម្រាប់ពលករកម្ពុជាដែលត្រឡប់ពីប្រទេសថៃ មកកាន់សហគមន៍ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប។ ស្វែងយល់ពីតួអង្គផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញរបស់ពលករចំណាកស្រុកនៅក្នុងខេត្តទាំងបីនេះ ព្រមទាំងតួនាទីរបស់ពួកគេក្នុងការគាំទ្រការធ្វើសមាហរណកម្មឡើងវិញរបស់ពលករចំណាកស្រុក និងចន្លោះប្រហោងដែលមាននៅក្នុងដំណើរការនៃការគាំទ្រនេះ។ បង្ហាញនូវការស្វែងយល់ជាកស្តុតាងនៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញនៃពលករចំណាកស្រុកពីប្រទេសថៃ មកកាន់ខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ដើម្បីបង្កើតផែនទីបង្ហាញផ្លូវដែលផ្តោតលើចន្លោះប្រហោងនៃសេវាកម្មដែលផ្តល់ឲ្យពលករចំណាកស្រុកដែលត្រឡប់មកវិញ ព្រមជាមួយនឹងអនុសាសន៍មួយចំនួនដែលអាចអនុវត្តបាន សម្រាប់កែលម្អដំណើរការនេះប្រកប ដោយចីរភាព។

អាស្រ័យដូចបានជម្រាបខាងលើ សូម **លោកជំទាវ** មេត្តាជួយចាត់អញ្ជើញសមាជិកគណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូរ ដើម្បីចូលរួមសិក្ខាសាលាស្តីពី ប្រសិទ្ធភាពនៃកម្មវិធីជំនួយក្នុងការវិលត្រលប់

ដោយស្ម័គ្រចិត្ត និងការធ្វើសមាហរណកម្ម នៅកម្ពុជា ***នៅព្រឹកថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២២*** និងកិច្ចប្រជុំគណៈប្រតិភូកម្ពុជាសម្រាប់កិច្ចពិភាក្សាត្រៀម មុនចូលរួមកិច្ចប្រជុំស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) នៃការអនុវត្តច្បាប់រវាងប្រទេសកម្ពុជា និងប្រទេសថៃ ***នៅរសៀលនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២២នៅសណ្ឋាគារកាំបូឌីយ៉ាណា បន្ទប់ទន្លេចតុមុខ។***

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **លោក ឯក សំអុល** តាមរយៈទូរស័ព្ទលេខ ០១២ ៩៣០ ៩១១ ឬ អ៊ីមែល sek@iom.int ។

ជូសមុខឱ្យអង្គការ IOM ខ្ញុំសូមថ្លែងអំណរគុណ **លោកជំទាវ** ចំពោះការគាំទ្រ និងភាពជាដៃគូជាមួយអង្គការ IOM ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២២

INTERNATIONAL ORGANIZATION FOR MIGRATION IOM CAMBODIA

Dr.YIN Setheka
IOM/OIM 9729

លោកស្រី **ក្រីស្ទីន ប៉ាកូ**
ប្រធានបេសកកម្ម
អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំកម្ពុជា

# Invitation to workshop on:
# The effectiveness of Return and Reintegration Assistance Programs in Cambodia

**Friday, 18th August 2022**
**Cambodiana Hotel, Room Tonle Chaktomuk**

## Introduction

The COVID-19 pandemic called into question the accessibility, relevance and effectiveness of voluntary return and reintegration assistance programs in Cambodia. More than 280,000 Cambodian migrant workers returned to Cambodia since March 2020 due to the impact of COVID-19 pandemic. The process of reintegration is challenging for returnees, especially so for those whose migration plan has been interrupted by a sudden need or pressure to return. Re-establishing one's life in a community of origin in a sustainable manner requires that returnees reach levels of economic self-sufficiency, social stability within their communities, and psychosocial well-being that allow them to cope with (re)migration drivers. IOM Cambodia has conducted a quick-dive study to assess these aspects in Banteay Meanchey, Siem Reap and Battambang provinces, the locations within Cambodia with the largest numbers of migrants who have returned due to the COVID-19 impact from Thailand. The study aims to assess the gaps in service provision which might have arisen due to the lack of the standard operating procedure (SOP) being implemented, or gaps which might be better addressed in the SOP, should it need to be revised to reflect the post-pandemic context.

## Objectives of the study

The main objective of the study is to evaluate the effectiveness of return and reintegration assistance programs in Cambodia and develop a road map to address gaps in the provision of related services. Specifically, this study aimed to:

1. Understand the experience of return and reintegration for Cambodian labour migrants returning from Thailand to communities in Banteay Meanchey, Battambang, and Siem Reap.
    a. Why do they migrate and why do they return?
    b. What kind of support do they seek and why?
    c. What kinds of support are forthcoming and why?
    d. Why do some migrants remigrate, and why do others choose to stay in Cambodia?
    e. What challenges pertaining to return migrants remain unresolved?
    f. What are the risks and rewards (for migrants) involved with the return and reintegration process as it currently stands?

2. Understand the various actors involved with migrants' return and reintegration process in this province, their roles in supporting returnees' reintegration, and the gaps existing in this support matrix.

3. Draw on evidenced understandings of return and reintegration of labour migrants from Thailand to Banteay Meanchey, Battambang, and Siem Reap to develop a road map targeting gaps in services provided to returned migrants with actionable recommendations for sustainably improving this process.

**Location:**

IOM would like to invite knowledgeable stakeholders to join our participatory workshop. The consultation workshop will be held in Cambodiana Hotel, Room Tonle Chaktomuk at the on 18th of August 2022 at 8.45am. This workshop will review, discuss and confirm prioritized findings and recommendations of the report. The results of this workshop will be used to shape the final report and create a road map to address gaps in the provision of services.

**Draft Agenda for the Consultation Workshop**

| Time | | Topic | Lead/Presenter |
|---|---|---|---|
| **Start** | **End** | | |
| 8.30 | 8.45 | **Registration** | |
| 8.45 | 9.00 | **Introduction**<br>- Remark by Markus Bell-Project Lead<br>- Welcome remarks by Chief of Mission<br>- Open remark by H.E Chou Bun Eng | Markus Bell – Project Lead |
| 9:00 | 9:15 | **Tea Break** | |
| 9.15 | 9.30 | **Background**<br>Review of the agenda<br>- Background to the research<br>- Methods employed<br>- Timeline of the research | Sreyneang Chhern – Project Qualitative Lead |
| 9.40 | 10.00 | **Topline results of the report**<br>- Presentation of the results by key theme | Todd Hunkin – Research Specialist |
| 10.00 | 10.20 | **Q&A on results**<br>- Open floor for questions from participants on the findings | Todd Hunkin – Research Specialist |
| 10.20 | 10.45 | **Recommendations of the report**<br>- Outline of recommendations in report | Markus Bell – Project Lead |
| 10.45 | 11.00 | **Q&A on recommendations**<br>- Questions from participants on the recommendations presented<br>- Open floor for participants to provide additional recommendations | Markus Bell – Project Lead |
| 11.00 | 11.40 | **Group discussion exercise on possible service provisions** | Sub-groups led by:<br>Markus Bell – Project Lead<br>Todd Hunkin – Research Specialist |
| 11.40 | 12.00 | **Wrap-up**<br>- Summary of the service provision mapping exercise<br>- Next steps for the report<br>- Photos | Markus Bell – Project Lead |

**<u>Participants List</u>**

### Government Actors

1. National Committee for Counter Trafficking

2. Ministry of Labor and Vocational Training, Department of Employment and Labor
3. Ministry of Foreign Affairs, Department of Consular Affairs
4. National Employment Agency, Siem Reap (+855 78 682 268)
5. Malai District Office of Social Affair and Welfare, Banteay Meanchey (+855 92 942 818)

**Non-Governmental Actors**

| | |
|---|---|
| 1. IJM | ssin@ijm.org |
| 2. Chab Dai coalition | chan.saron@chabdai.org |
| 3. CENTRAL | +855 93 556 616 |
| 4. Sok Chomnol Co.,LTD | +855 98 666 060 |
| 5. A.P.T.S. E&C (Cambodia) | +855 71 995 5668 |
| 6. Premium Manpower Co.,LTD | sambannay@gmail.com |

ការអញ្ជើញចូលរួមសិក្ខាសាលាស្ដីពីៈ
ប្រសិទ្ធភាពនៃកម្មវិធីជំនួយគ្រឡប់ និងសមាហរណកម្មឡើងវិញនៅកម្ពុជា

ថ្ងៃសុក្រ ទី១៨ ខែសីហា ឆ្នាំ២០២២
**នៅសណ្ឋាគារកាំបូឌីយ៉ាណាបន្ទប់ទន្លេចតុមុខ**

## សេចក្ដីផ្ដើម

ជម្ងឺរីករាលដាលកូវីដ-១៩ បានចោទជាសំនួរអំពីលទ្ធភាពក្នុងការប្រើប្រាស់ ភាពពាក់ព័ន្ធ និងប្រសិទ្ធភាពនៃកម្មវិធីជំនួយ និងការធ្វើសមាហរណកម្មឡើងវិញដោយស្ម័គ្រចិត្តនៅក្នុងប្រទេសកម្ពុជា។ ពលករចំណាកស្រុកខ្មែរចំនួនជាង ២៨ ម៉ឺននាក់ បានត្រឡប់មកប្រទេសកម្ពុជាវិញចាប់តាំងពីខែមីនា ឆ្នាំ២០២០ ដោយសារឥទ្ធិពលនៃជម្ងឺរីករាលដាលកូវីដ-១៩។ ដំណើរការនៃការធ្វើសមាហរណកម្មឡើងវិញជួបប្រទះនូវបញ្ហាប្រឈមសម្រាប់អ្នកត្រឡប់មកប្រទេសវិញ ជាពិសេសសម្រាប់អ្នកដែលមានផែនការធ្វើចំណាកស្រុក ហើយត្រូវបានអាក់ខានភ្លាមៗ ឬទទួលរងសម្ពាធឲ្យវិលត្រឡប់មកវិញ។ ការសម្របជីវិតរស់នៅរបស់មនុស្សម្នាក់ឡើងវិញនៅក្នុងសហគមន៍ដើមប្រកបដោយនិរន្តរភាព តម្រូវឱ្យអ្នកត្រឡប់មកវិញឈានដល់កម្រិតគ្រប់គ្រាន់ផ្នែកសេដ្ឋកិច្ច ស្ថិរភាពសង្គមនៅក្នុងសហគមន៍របស់ពួកគេ និងសុខុមាលភាពផ្លូវចិត្តដែលអនុញ្ញាតឱ្យពួកគេជម្នះបាននឹង (ការធ្វើចំណាកស្រុកម្ដងទៀត) កត្តាអូសទាញទៅរកការចំណាកស្រុក។ អង្គការ IOM នៅប្រទេសកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវភ្លាមៗមួយដើម្បីវាយតម្លៃទិដ្ឋភាពទាំងនេះនៅក្នុងខេត្តបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង ដែលជាតំបន់ដែលមានចំនួនជនចំណាកស្រុកច្រើនជាងគេដែលបានត្រឡប់មកប្រទេសកម្ពុជាវិញដោយសារតែផលប៉ះពាល់ពីកូវីដ-១៩ ពីប្រទេសថៃ។ ការសិក្សានេះមានគោលបំណងវាយតម្លៃនូវចន្លោះប្រហោងនៅក្នុងការផ្ដល់សេវាដែលអាចកើតឡើងដោយសារកង្វះខាតនៃនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) ដែលកំពុងត្រូវបានអនុវត្ត ឬចន្លោះប្រហោងដែលអាចនឹងត្រូវបានដោះស្រាយឲ្យបានប្រសើរឡើងនូវនីតិវិធីប្រតិបត្តិការស្តង់ដារ ប្រសិនបើមានការចាំបាច់ត្រូវកែសម្រួលដើម្បីឆ្លុះបញ្ចាំងនូវបរិបទក្រោយជម្ងឺរីករាលដាល។

## គោលបំណងនៃការសិក្សា

គោលបំណងសំខាន់នៃការសិក្សានេះគឺធ្វការវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីជំនួយត្រឡប់ និងសមាហរណកម្មឡើងវិញក្នុងប្រទេសកម្ពុជា និងបង្កើតផែនទីបង្ហាញផ្លូវដើម្បីដោះស្រាយនូវចន្លោះប្រហោងក្នុងការផ្ដល់សេវាដែលពាក់ព័ន្ធ។ ជាពិសេស ការសិក្សានេះមានគោលបំណងៈ

១. ស្វែងយល់ពីបទពិសោធន៍នៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មសម្រាប់ពលករកម្ពុជាដែលត្រឡប់ពីប្រទេសថៃ មកកាន់សហគមន៍ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប។

ក. ហេតុអ្វីបានជាពួកគេធ្វើចំណាកស្រុក ហើយមូលហេតុអ្វីទើបពួកគេត្រឡប់មកវិញ?

ខ. តើការគាំទ្រប្រភេទណាដែលពួកគេស្វែងរក និងដោយមូលហេតុអ្វី?

គ. តើការគាំទ្រប្រភេទណាខ្លះដែលនឹងមាននៅពេលខាងមុខ និងដោយមូលហេតុអ្វី?

ឃ. ហេតុអ្វីបានជាពលករចំណាកស្រុកខ្លះធ្វើចំណាកស្រុកម្តងទៀត ហើយហេតុអ្វីបានជាពលករចំណាកស្រុកផ្សេងទៀតជ្រើសរើសស្នាក់នៅក្នុងប្រទេសកម្ពុជា?

ង. តើបញ្ហាប្រឈមអ្វីខ្លះដែលនៅតែមិនទាន់មានដំណោះស្រាយទាក់ទងនឹងការវិលត្រឡប់របស់ពលករចំណាកស្រុក?

ច. តើមានហានិភ័យ និងអត្ថប្រយោជន៍អ្វីខ្លះ (សម្រាប់ពលករចំណាកស្រុក) ដែលពាក់ព័ន្ធនឹងដំណើរការនៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញដែលកំពុងមានស្រាប់?

២. ស្វែងយល់ពីតួអង្គផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញរបស់ពលករចំណាកស្រុកនៅក្នុងខេត្តនេះ ព្រមទាំងតួនាទីរបស់ពួកគេក្នុងការគាំទ្រការធ្វើសមាហរណកម្មឡើងវិញរបស់ពលករចំណាកស្រុក និងចន្លោះប្រហោងដែលមាននៅក្នុងដំណើរការនៃការគាំទ្រនេះ។

៣. បង្ហាញនូវការស្វែងយល់ជាភស្តុតាងនៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មឡើងវិញនៃពលករចំណាកស្រុកពីប្រទេសថៃ មកកាន់ខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ដើម្បីបង្កើតផែនទីបង្ហាញផ្លូវដែលផ្តោតលើចន្លោះប្រហោងនៃសេវាកម្មដែលផ្តល់ឲ្យពលករចំណាកស្រុកដែលត្រឡប់មកវិញ ព្រមជាមួយនឹងអនុសាសន៍មួយចំនួនដែលអាចអនុវត្តបាន សម្រាប់កែលម្អដំណើរការនេះប្រកប ដោយចីរភាព។

**ទីតាំង**

IOM សូមគោរពអញ្ជើញអ្នកដែលពាក់ព័ន្ធចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់របស់យើង។ សិក្ខាសាលាពិគ្រោះយោបល់នេះនឹងប្រព្រឹត្តទៅនៅ**រាជធានីភ្នំពេញ នៅសណ្ឋាគារកាំបូឌីយ៉ាណាបន្ទប់ទន្លេចតុមុខ នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២២ វេលាម៉ោង ៨:៤៥ នាទីព្រឹក។** សិក្ខាសាលានេះនឹងធ្វើការពិនិត្យ ពិភាក្សា និងបញ្ជាក់ការរកឃើញអាទិភាព និងអនុសាសន៍នៅក្នុងរបាយការណ៍។ លទ្ធផលនៃសិក្ខាសាលានេះនឹងត្រូវប្រើដើម្បីរៀបចំធ្វើរបាយការណ៍ចុងក្រោយ និងបង្កើតផែនទីបង្ហាញផ្លូវដើម្បីដោះស្រាយចន្លោះប្រហោងក្នុងការផ្តល់សេវា។

## សេចក្តីព្រាងរបៀបវារៈនៃសិក្ខាសាលាពិគ្រោះយោបល់

| ម៉ោង | | ប្រធានបទ | អ្នកសម្របសម្រួល/អ្នកធ្វើបទបង្ហាញ |
|---|---|---|---|
| ផ្តើម | បញ្ចប់ | | |
| 8.30 | 8.45 | **ការចុះឈ្មោះ** | |
| 8.45 | 9.00 | **សេចក្តីផ្តើម**<br>- ចំណាប់អារម្មណ៍លោកម៉ាកូស ប៊ែល អ្នកដឹកនាំការសិក្សាស្រាវជ្រាវ<br>- មតិស្វាគមន៍របស់លោកស្រី គ្រីស្ទីន ជាកូប្រធានបេសកម្មIOM ប្រចាំប្រទេសកម្ពុជា<br>- ការថ្លែងសន្ទរកថាបើកកម្មវិធីរបស់លោកជំទាវជូប៊ុនអេងរដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃនៃគ.ជ.ប.ជ | Markus Bell – អ្នកដឹកនាំការសិក្សាស្រាវជ្រាវ |
| | | **សម្រាកអាហារសម្រន់** | |
| 9.15 | 9.30 | **សារតា**<br>- បង្ហាញរបៀបវារៈកម្មវិធី- សារតានៃការសិក្សស្រាវជ្រាវ<br>- វិធីសាស្ត្រនៃការសិក្សស្រាវជ្រាវ<br>- រយៈពេលនៃការសិក្សស្រាវជ្រាវ | ឈឿន ស្រីនាង – អ្នកស្រាវជ្រាវគុណវិស័យ |
| 9.40 | 10.00 | **លទ្ធផលសំខាន់ៗនៃរបាយការណ៍ស្រាវជ្រាវ**<br>- បទបង្ហាញពីលទ្ធផលសំខាន់ៗតាមផ្នែកនីមួយៗ | Todd Hunkin – អ្នកឯកទេសស្រាវជ្រាវ |
| 10.00 | 10.20 | **សំនួរ និងចម្លើយអំពីលទ្ធផល**<br>- សំនួរពីអ្នកចូលរួមទាក់ទងនឹងលទ្ធផលដែលរកឃើញ | Todd Hunkin – អ្នកឯកទេសស្រាវជ្រាវ |
| 10.20 | 10.45 | **អនុសាសន៍នៃរបាយការណ៍ស្រាវជ្រាវ**<br>- បង្ហាញអនុសាសន៍នៅក្នុងរបាយការណ៍ | Markus Bell – អ្នកដឹកនាំការសិក្សាស្រាវជ្រាវ |
| 10.45 | 11.00 | **សំនួរ និងចម្លើយអំពីអនុសាសន៍**<br>- សំនួរពីអ្នកចូលរួមទាក់ទងនឹងអនុសាសន៍ដែលបានបង្ហាញ<br>- បើកឱកាសឲ្យអ្នកចូលរួមផ្តល់អនុសាសន៍បន្ថែម<br>- | Markus Bell – អ្នកដឹកនាំការសិក្សាស្រាវជ្រាវ |
| 11.00 | 11.40 | **ការពិភាក្សាក្រុមផ្តោតលើសេវាដែលគួរតែផ្តល់ឲ្យ** | Sub-groups led by: Markus Bell – អ្នកដឹកនាំការសិក្សាស្រាវជ្រាវ Todd Hunkin – អ្នកឯកទេសស្រាវជ្រាវ |

| | | | |
|---|---|---|---|
| 11.40 | 12.00 | **សង្ខេប**<br>- សង្ខេបការធ្វើផែនទីនៃការផ្តល់សេវា<br>- ជំហានបន្ទាប់នៃការធ្វើរបាយការណ៍<br>- ថតរូប | Markus Bell – អ្នកដឹកនាំការសិក្សាស្រាវជ្រាវ |

## <u>បញ្ជីឈ្មោះអ្នកចូលរួម</u>

### តួអង្គរាជរដ្ឋាភិបាល

1. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
2. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (នាយកដ្ឋានការងារ និងមុខរបរ)
3. ក្រសួងការបរទេស (នាយកដ្ឋានកិច្ចការកុងស៊ុល)
4. ទីភ្នាក់ងារជាតិមុខរបរ ខេត្តសៀមរាប (លេខទំនាក់ទំនង៖ +855 78 682 268)
5. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ (លេខទំនាក់ទំនង៖ +855 92 942 818)
6. ????

### តួអង្គមិនមែនរាជរដ្ឋាភិបាល

1. IJM — ssin@ijm.org
2. Chab Dai coalition — chan.saron@chabdai.org
3. CENTRAL — +855 93 556 616
4. Sok Chomnol Co.,LTD — +855 98 666 060
5. A.P.T.S. E&C (Cambodia) — +855 71 995 5668
6. Premium Manpower Co.,LTD — sambannay@gmail.com
7. ???